**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

# និទានអំណានជាតិលើកទី៩

## ការប្រឡងប្រជែងបកស្រាយប្រធានបទ

## «តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌និងចរិយាធម៌»

| | |
|---|---|
| **ស្រាវជ្រាវដោយ៖** | **បេក្ខជន សាត ឌិច គេង ប្រុស** |
| **ថ្ងៃខែឆ្នាំកំណើត៖** | **០៣ មេសា ១៩៩១** |
| **ទីកន្លែងកំណើត៖** | **ភូមិកែបក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប** |
| **តួនាទី៖** | **គ្រូបង្រៀន** |
| **អង្គភាពបម្រើការងារ៖** | **នៅវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ចរិយាវង្ស** |
| **លេខទូរសព្ទ៖** | **០៨៨ ៧៩៩ ២៩៩ ៦** |
| **បេក្ខជនមកពី៖** | **ខេត្តកែប** |

**ឆ្នាំ២០២៤**

មាតិកា ទំព័រ

**ជំពូក១ សេចក្តីផ្តើម** ............................................................ ១

**ជំពូក២ ទ្រឹស្តីពាក់ព័ន្ធ**............................................................ ២

២.១.អំពីព្រះពុទ្ធសាសនា............................................................ ២

២.១.១.និយមន័យ............................................................ ២

២.១.២.វត្តមានពុទ្ធសាសនានៅកម្ពុជា............................................................ ២

២.១.៣.គម្ពីរព្រះត្រៃបិដក............................................................ ៤

២.១.៤.អរិយសច្ច ឬ ចតុរារិយសច្ច............................................................ ៥

២.១.៥.ទស្សនៈកម្ម-ផល............................................................ ៥

២.២.អំពីសីលធម៌និងចរិយាធម៌............................................................ ៦

២.២.១.និយមន័យសីលធម៌............................................................ ៦

២.២.២.និយមន័យចរិយាធម៌............................................................ ៦

**ជំពូក៣ បញ្ហាសីលធម៌និងចរិយាធម៌នៅក្នុងសង្គមខ្មែរ**............................................................ ៧

៣.១.ការស្រុតចុះនៃតម្លៃសីលធម៌ក្នុងសង្គមខ្មែរ............................................................ ៧

៣.២.ផលប៉ះពាល់នៃការធ្លាក់ចុះសីលធម៌............................................................ ៩

៣.៣.ការលើកកម្ពស់សីលធម៌ក្នុងសង្គម............................................................ ៩

**ជំពូក៤ ពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌និងចរិយាធម៌**............................................................ ១១

៤.១.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈបុណ្យទេសនាទសជាតក............................................................ ១១

៤.២.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈសីល៥............................................................ ១១

៤.៣.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈព្រហ្មវិហារធម៌....................................១២

៤.៤.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈគោលធម៌៨យ៉ាង..................................១២

៤.៥.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈអំពើល្អ១០យ៉ាង..................................១៣

៤.៥.១.អំពើប្រព្រឹត្តល្អដោយកាយ៣ (កាយសុចរិត).....................................១៣

៤.៥.២.អំពើប្រព្រឹត្តល្អដោយវាចា៤ (វិចីសុចរិត...........................................១៣

៤.៥.៣.អំពើប្រព្រឹត្តល្អដោយចិត្ត៣ (មនោសុចរិត).......................................១៣

៤.៦.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈក្រមសីលធម៌ទាំង៥ ...............................១៤

៤.៦.១.សីលធម៌ផ្ទាល់ខ្លួន ........................................................................១៤

៤.៦.២.សីលធម៌ក្នុងគ្រួសារ ....................................................................១៤

៤.៦.៣.សីលធម៌ក្នុងវិជ្ជាជីវៈ ....................................................................១៤

៤.៦.៤.សីលធម៌ក្នុងសង្គម ......................................................................១៥

៤.៦.៥.សីលធម៌ក្នុងពិភពលោក ...............................................................១៥

៤.៧.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈការដឹងពីតួនាទី ...................................១៥

៤.៧.១.តួនាទីមាតាបិតា.........................................................................១៥

៤.៧.២.តួនាទីកូន...................................................................................១៦

៤.៧.៣.តួនាទីស្វាមី.................................................................................១៦

៤.៧.៤.តួនាទីភរិយា................................................................................១៦

៤.៧.៥.តួនាទីគ្រូបាអាចារ្យ......................................................................១៦

៤.៧.៦.តួនាទីសិស្ស៥យ៉ាង......................................................................១៧

៤.៧.៧.តួនាទីចៅហ្វាយនាយ..............................................................................១៧

៤.៧.៨.តួនាទីទាសកម្មករឬអ្នកបម្រើ.......................................................................១៧

៤.៧.៩.តួនាទីមិត្តល្អ..............................................................................................១៧

៤.៨.គុណតម្លៃនៃព្រះពុទ្ធសាសនា..........................................................................១៧

៤.៨.១.ប្រយោជន៍ចំពោះបុគ្គល.............................................................................១៧

៤.៨.២.ប្រយោជន៍ចំពោះសង្គម .............................................................................១៨

**ជំពូក៥ សេចក្តីសន្និដ្ឋាននិងអនុសាសន៍** ..............................................................................១៩

ឯកសារយោង.......................................................................................................២០

# ជំពូក១ សេចក្តីផ្តើម

ព្រះពុទ្ធសាសនា ជាសាសនាមួយដែលមានអ្នកកាន់រហូតដល់ទៅរាប់រយលាននាក់ ហើយបានរីកសាយភាយស្ទើរពាសពេញពិភពលោក។ អ្នកប្រាជ្ញជាច្រើនបានអះអាងថា ព្រះពុទ្ធសាសនា ជាសាសនាមួយមានហេតុផលគ្រប់គ្រាន់ ហើយត្រឹមត្រូវបំផុត។ ចំពោះឱវាទ ឬពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មានលក្ខណៈជារបស់មនុស្សសុទ្ធសាធ ដែលឆ្លើយតបទៅនឹងបញ្ហារបស់មនុស្សតែម្តង។

កម្ពុជាបានកំណត់យកព្រះពុទ្ធសាសនា គឺជាសាសនារបស់រដ្ឋ ហើយទ្រឹស្តីព្រះពុទ្ធតែងតែអប់រំទូន្មានឱ្យមនុស្សប្រព្រឹត្តអំពើល្អ អំពើជាកុសល ដោយចៀសវាងការប្រព្រឹត្តអំពើបាបគ្រប់បែបយ៉ាង ហើយមានគោលបំណងរក្សាសន្តិភាព។ ការអប់រំនោះទៀតសោត គឺឱ្យមនុស្សមានមេត្តាដល់គ្នា ប្រាសចាកកិលេសតណ្ហា និងការបៀតបៀនសត្វលោក។ ពិសេសជាសាសនានៃបញ្ញា មានករុណា និងណែនាំឱ្យមនុស្សមានការអើពើជួយដល់គ្នានឹងគ្នា មិនបែងចែកវណ្ណៈក្នុងរឿងភេទស្រីប្រុសឡើយ ហើយក៏បានសាបព្រោះនូវសីលធម៌ឱ្យដុះដាលក្នុងខ្លួនមនុស្សគ្រប់គ្នាផងដែរ។ ការបណ្តុះបណ្តាលសីលធម៌នៅក្នុងខ្លួននេះ វាប្រៀបដូចជាការសាងសិរីសួស្តីឱ្យខ្លួនឯងអ៊ីចឹង។ ប៉ុន្តែមនុស្សជាច្រើន មិនយល់ពីតម្លៃនៃសីលធម៌ ចរិយាធម៌ ដែលត្រូវចម្រើនក្នុងខ្លួននោះទេ ដូចជាការគោរព សំពះ ថ្វាយបង្គំ បម្រើជាដើម។ នេះដូចយើងបានឃើញស្រាប់ហើយថា សីលធម៌របស់មនុស្សសព្វថ្ងៃ គឺកាន់តែធ្លាក់ចុះទៅៗគួរឱ្យព្រួយបារម្ភ។

ជាការពិត សីលធម៌របស់មនុស្ស គឺជាគ្រឿងលម្អជីវិត។ ប៉ុន្តែបើសង្គមមួយទាំងមូល ហើយមនុស្សគ្រប់គ្នាកាន់តែឃ្លាតឆ្ងាយពីសីលធម៌ លែងអើពើនឹងសីលធម៌ ច្បាស់ណាស់សង្គមនោះនឹងគ្មានសណ្តាប់ធ្នាប់ គ្មានច្បាប់ទម្លាប់ គ្មានសន្តិភាព។ល។ ក្នុងករណីនេះ តើព្រះពុទ្ធសាសនាបានរួមចំណែកអ្វីខ្លះក្នុងការលើកកម្ពស់ការអប់រំសីលធម៌និងចរិយាធម៌? ហើយព្រះពុទ្ធសាសនានោះទៀតសោតមានតួនាទីអ្វីខ្លះក្នុងការបណ្តុះសីលធម៌មនុស្សនៅក្នុងសង្គម ដើម្បីឱ្យមនុស្សចេះរស់នៅជាមួយគ្នាដោយភារតភាព?

## ជំពូក២ ទ្រឹស្ដីពាក់ព័ន្ធ

## ២.១.អំពីព្រះពុទ្ធសាសនា

### ២.១.១.និយមន័យ

**សាសនា**[1] ជាពាក្យក្លាយមកពីបាលី និងសំស្ក្រឹតថា **សាសនៈ** ដែលបានពន្យល់ថា ជាពាក្យបណ្ដាំ ពាក្យផ្ដាំផ្ញើ ពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅ លទ្ធិ ពាក្យបង្គាប់ ការបង្គាប់បញ្ជា ដំណឹងសំបុត្រ ពាក្យប្រកាស ការប្រកាសប្រាប់ ការជឿស្ដាប់ ការដាក់ទណ្ឌកម្ម ការផ្ដន្ទាទោស ការកែសម្រួល ការគ្រប់គ្រង ការត្រួតត្រា...។ ពាក្យ **សាសនៈ** មានន័យច្រើន ប៉ុន្តែក្នុងពេលនេះយើងសូមលើកយកតែត្រឹមពាក្យ បណ្ដាំ ពាក្យប្រៀនប្រដៅ ឬ ការប្រៀនប្រដៅតែប៉ុណ្ណោះ ដើម្បីឱ្យស៊ីគ្នានឹងពាក្យសាសនាដែលត្រូវគ្នានឹងពាក្យបារាំងថា Religion ។[2]

ដូច្នេះគេអាចឱ្យនិយមន័យ **សាសនា** ជាពាក្យបណ្ដាំ ឬការទូន្មានប្រៀនប្រដៅរបស់គ្រូអាចារ្យណាមួយនៅក្នុងលោក។ ចំណែក«**ព្រះពុទ្ធសាសនា**» ជាពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធដែលព្រះអង្គរកឃើញនូវមោក្ខធម៌ ដើម្បីដឹកនាំមនុស្សសត្វទៅរកឋានរម្ងាប់ទុក្ខ។

### ២.១.២.វត្តមានពុទ្ធសាសនានៅកម្ពុជា

ព្រះពុទ្ធសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌា ហើយត្រូវបានផ្សព្វផ្សាយនៅលើបណ្ដាប្រទេសនានានៅលើសាកលលោក ជាពិសេសនៅបណ្ដាប្រទេសមួយចំនួននៃភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។ ដោយឡែកនៅប្រទេសកម្ពុជា ព្រះពុទ្ធសាសនាបានចូលមកដល់តាំងពីយូរយារណាស់មកហើយ ព្រមទាំងបានជះឥទ្ធិពលខ្លាំង រហូតធ្វើឱ្យដក់ជាប់យ៉ាងជ្រាលជ្រៅក្នុងក្រអៅបេះដូងនៃចិត្តគំនិតទំនៀមទម្លាប់ប្រពៃណី សិល្បៈ វប្បធម៌នៃមនុស្សខ្មែរយើង។ ចំពោះកាលបរិច្ឆេទនៃការចូលមកដល់ ឬវត្តមាននៃព្រះពុទ្ធសាសនានៅកម្ពុជា គឺជាបញ្ហាមួយដែលអ្នកសិក្សាប្រវត្តិសាស្ត្រក៏ដូចជាអ្នកសិក្សាអក្សរសាស្ត្រនិងវប្បធម៌ អរិយធម៌ តែងតែចោទសួរថា តើព្រះពុទ្ធសាសនាបានចូលមកប្រទេសកម្ពុជាយើងតាំងពីពេលណា? ហើយគេតែងប្រៀបធៀបទៅនឹងវត្តមាននៃលទ្ធិព្រហ្មញ្ញសាសនាផងដែរ តើលទ្ធិសាសនាចូលមកដល់កម្ពុជានៅពេលណា? បញ្ហានេះក៏មានអ្នកសិក្សាជាច្រើនបានឱ្យយោបល់

[1] វចនានុក្រមខ្មែរ សម្ដេចសង្ឃរាជ ជួន ណាត ទំព័រ១៣៧៣

[2] បណ្ឌិត ធ សោ ឆ្នាំ១៩៩៤ ព្រះពុទ្ធសាសនា និងសង្គមខ្មែរទំព័រទី៧-៨

ខុសៗគ្នា។ ដោយអ្នកសិក្សាខ្លះឱ្យយោបល់ថា ព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសកម្ពុជា តាំងពី ស.វ.ទី៣ ឬស.វ.ទី២មុនគ.ស. ដោយសំអាងលើប្រវត្តិសាស្ត្រនៃព្រះបាទធម្មាសោកនៃប្រទេសឥណ្ឌា ដែលព្រះអង្គជាមហាពុទ្ធសាសនិកជនមួយរូប គោរពព្រះពុទ្ធសាសនាថេរវាទ បានបញ្ជូនសមណទូត ពីរអង្គ សោណត្ថេរនិងឧត្តរត្ថេរ ដើម្បីមកផ្សព្វផ្សាយព្រះពុទ្ធសាសនានៅដែនដីសុវណ្ណភូមិ។ បញ្ហានេះ ក៏ត្រូវបានបញ្ជាក់ដោយសម្តេចព្រះមហាសុមេធាធិបតី ហួត តាត វជិរប្បញ្ញោ ព្រះសង្ឃនាយកគណៈ មហានិកាយ ព្រះអង្គទ្រង់បានសរសេរក្នុងស្នាដៃរបស់ព្រះអង្គ (ព្រះពុទ្ធសាសនានៅកម្ពុជាសង្ខេប បោះពុម្ពលើកទី២ នៅគ.ស.១៩៧០ ទំព័រទី១) ថា «ព្រះពុទ្ធសាសនាផ្សាយចូលមកប្រទេសកម្ពុជាមុន ដំបូងតាមគម្ពីរពុទ្ធសាសនាសមន្តបាសទិកាអដ្ឋកថា វិន័យបិដក ជាភាសាបាលីបានប្រាប់ព័ត៌មានថា កាលក្រោយពេលដែលធ្វើតតិយសង្គាយនារួចហើយ នៅក្នុងជម្ពូទ្វីប គឺប្រទេសឥណ្ឌាក្នុងពុទ្ធសតវត្សទី ៣ ព្រះមហាថេរមួយអង្គព្រះនាម មហាមោគ្គលិបតិស្សៈ បានបញ្ជូនព្រះថេរ២អង្គ គឺព្រះសោណត្ថេរនិង ព្រះឧត្តរត្ថេរឱ្យចេញពីជម្ពូទ្វីប(ឥណ្ឌា)មកផ្សាយព្រះពុទ្ធសាសនា នៅសុវណ្ណភូមិក្នុងព្រះបរមរាជបត្តម្ភ នៃព្រះមហាក្សត្រ ព្រះនាមធម្មសោក»។

ចំណែកអ្នកសិក្សាខ្លះទៀតបានឱ្យយោបល់ថា ព្រះពុទ្ធសាសនាបានចូលមកប្រទេសខ្មែរយើង នៅសតវត្សទី២នៃគ្រឹស្តសករាជទៅវិញ។ បញ្ហានេះអ្នកស្រី ត្រឹងងា សរសេរក្នុងស្នាដៃ អរិយធម៌ខ្មែរ បោះពុម្ពឆ្នាំ១៩៧៣ ទំព័រ៨០ ថាៈ តាមសិលាចារឹក វ៉ូ កាញ់ (យួនខាងត្បូង) ទំនងជាព្រះពុទ្ធសាសនា ចូលរួមមកប្រតិស្ថានក្នុងស្រុកខ្មែរនៅសតវត្សទី២នៃគ្រឹស្តសករាជក្នុងរជ្ជកាលព្រះបាទស្រីមារៈ ឬហ្វាន់ ចេម៉ាន់។ ប៉ុន្តែទស្សនៈខ្លះគេបានពន្យល់ថា ព្រះពុទ្ធសាសនាមានកំណើតក្រោយព្រហ្មញ្ញសាសនា ដោយប្រហែលជានឹងអាចចូលមកដល់កម្ពុជាក្រោយការចូលមកដល់នៃលទ្ធិសាសនាព្រាហ្មណ៍ ពេល គឺក្រោយសតវត្សទី១នៃគ.ស. ដែលជាកាលកំណត់នៃការចូលរួមដល់នៃលទ្ធិព្រហ្មញ្ញសាសនា។ ដោយឡែកអ្នកខ្លះឱ្យយោបល់ថា ព្រះពុទ្ធសាសនានិងព្រហ្មញ្ញសាសនាបានចូលមកប្រទេសកម្ពុជា យើងក្នុងដំណាក់កាលប្រហាក់ប្រហែលគ្នា ឬមុនក្រោយបន្តិចបន្តួចប៉ុណ្ណោះ។ គេបានពន្យល់ថា បញ្ហា នេះគ្មានឯកសារណាមួយបញ្ជាក់ឱ្យច្បាស់ទេ ព្រោះគេហាក់ដូចជាពុំទាន់មានជំនឿចិត្តចំពោះទស្សនៈ អ្នកសិក្សាឯទៀតដែលយល់ថាសាសនានេះ ឬសាសនានោះមកដល់មុនឡើយ។

យើងពិនិត្យឃើញថា យោបល់ទាំងអស់ហាក់ដូចជាមានការឯកភាពគ្នាមួយនៅត្រង់ព្រះពុទ្ធ សាសនា ក៏ដូចជាព្រហ្មញ្ញសាសនាបានចូលមកដល់ប្រទេសកម្ពុជាយើងតាំងពីយូរយារណាស់មក ហើយ។ ដូច្នេះប្រទេសកម្ពុជាយើង ជាប្រទេសមួយមានអធិបតេយ្យភាពចំណាស់ជាងគេ ហើយបាន

ទទួលនិងគោរពព្រះពុទ្ធសាសនាមុតមាំជាងគេ ដែលសក្តិសមជាដែនដីសុវណ្ណភូមិដែលទទួលការផ្សព្វផ្សាយព្រះពុទ្ធសាសនាដោយផ្ទាល់ពីសំណាក់សមណទូតពីរអង្គ ព្រះនាមសោណត្ថេរនិងឧត្តរត្ថេរ ក្រោមព្រះរាជបត្ថម្ភនៃព្រះបាទធម្មាសោកនាសតវត្សទី៣ ឬទី២ មុនគ.ស។[3]

### ២.១.៣.គម្ពីរព្រះត្រៃបិដក

នាពេលបច្ចុប្បន្ននេះ ព្រះពុទ្ធសាសនា ជាសាសនាមួយដែលមានអ្នកកាន់រហូតដល់ទៅរាប់សិបលាននាក់នៅលើពិភពលោក។ អត្រានៃប្រជាជនដែលមានជំនឿនិងគោរពចំពោះព្រះពុទ្ធសាសនាប្រមាណជាជាង៥០០លាននាក់[4] ដែលរស់នៅលើទឹកដីលាតសន្ធឹងពីដែនកោះស្រីលង្កាដល់ដែនកោះជប៉ុន ហើយស្ទើរពេញផ្ទៃដីគោកនៅក្នុងទ្វីបអាស៊ីទាំងមូល។ នៅក្នុងនោះ ព្រះពុទ្ធសាសនា មានគម្ពីរព្រះត្រៃបិដកជាគោល ហើយគម្ពីរនេះទៀតសោតជាឃ្លាំងផ្ទុកនូវពុទ្ធវចនៈសរុប៨៤.០០០ព្រះធម្មក្ខន្ធដែលជាមូលដ្ឋានទ្រឹស្តីទ្រទ្រង់ពុទ្ធសាសនា។គម្ពីរព្រះត្រៃបិដកត្រូវបានចែកចេញជាបីគម្ពីរសំខាន់ៗគឺៈ

- **វិន័យបិដក ៖** ជាគម្ពីរស្តីអំពីច្បាប់ ក្រឹត្យក្រម ដែលព្រះពុទ្ធអង្គទ្រង់បានបញ្ញត្តិ ហាមប្រាម និងទ្រង់អនុញ្ញាតទុកសម្រាប់ជាគោលប្រព្រឹត្តប្រតិបត្តិនៃបព្វជិតនិងគ្រហស្ថ ដែលជាភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី ឧបាសក ឧបាសិកា ទាយក ទាយិកា...។ គម្ពីរវិន័យបិដកជាកញ្ចក់សម្រាប់ឆ្លុះមើលនូវជីវប្រវត្តិ ជីវភាព សកម្មភាព សម្រាប់ឆ្លុះមើលនូវជីវភាព សកម្មភាពរបស់ព្រះសម្មាសម្ពុទ្ធ និងការអប់រំទូន្មានប្រៀនប្រដៅពុទ្ធបរិស័ទនិងសាវ័កដើម្បីផ្សាយសច្ចធម៌ក្នុងពេលដែលព្រះអង្គគង់មានព្រះជន្មនៅឡើយ។ មិនតែប៉ុណ្ណោះគម្ពីរវិន័យបិដកជាឯកសារមួយដ៏សំខាន់ ដែលបង្ហាញព្រឹត្តិការណ៍ផ្សេងៗក្នុងប្រទេសឥណ្ឌាដូចជា ការគ្រប់គ្រងប្រទេស របៀបរស់នៅ ផ្នែកប្រវត្តិសាស្ត្រ ប្រពៃណីទំនៀមទម្លាប់ សិល្បៈ វិជ្ជាផ្សេងៗ។ល។[5]
- **សុត្តន្តបិដក ៖** ជាគម្ពីរស្តីអំពីអត្ថបទធម៌ ដែលព្រះអង្គទ្រង់ទេសនាពន្យល់ ប្រោសមនុស្ស សត្វឱ្យប្រព្រឹត្តល្អ ស្គាល់បុណ្យបាប ល្អអាក្រក់...ក្នុងសម័យកាលផ្សេងៗ ហើយមានសូត្រខ្លះ សាវ័កសម្តែងប្រោសពន្យល់ពួកបរិស័ទមានសារីបុត្រ មោគ្គលាន អានន្ទជាដើម។

[៣] ព្រះពុទ្ធសាសនា និង សង្គមខ្មែរ បណ្ឌិត ធ សោ ឆ្នាំ១៩៩៤ ទំព័រទី ៤៦-៥២

[៤] សាស្ត្រាចារ្យ ស៊ិន គង់ បោះពុម្ពលើកទី២ ឆ្នាំ២០១៣ ឈ្វេងយល់ពីព្រះពុទ្ធសាសនាទំព័រទី១

[៥] បណ្ឌិត ធ សោ សាស្ត្រាចារ្យ អក្សរសាស្ត្រ និង វប្បធម៌ អរិយធម៌ខ្មែរ ឆ្នាំ១៩៩៤ ទំព័រទី២២

- **អភិធម្មបិដក ៖** ជាគម្ពីរស្តីអំពីធម៌អាថ៌ អត្ថបទធម៌ដ៏ជ្រាលជ្រៅល្អិតសុខុមជាបរមត្ថវិជ្ជា បានដល់ទស្សនវិជ្ជាព្រះពុទ្ធសាសនា ដែលចែកអំពីចិត្តចេតសិក រូប និព្វាន។

## ២.១.៤.អរិយសច្ច ឬ ចតុរារិយសច្ច

- **ទុក្ខអរិយសច្ចៈ** ៖ ជាបណ្តាទុក្ខដែលកើតមានដល់មនុស្សនិងសត្វគ្រប់រូប ហើយពុំអាចចៀសផុតបានឡើយ គ្រាន់តែអ្នកខ្លះមានទុក្ខតិច អ្នកខ្លះមានទុក្ខច្រើនប៉ុណ្ណោះ។
- **សមុទយអរិសច្ចៈ** ៖ ជាមូលហេតុនាំឱ្យកើតទុក្ខ ហើយហេតុនាំឱ្យមានទុក្ខ គឺតណ្ហានិងអវិជ្ជា។
- **និរោធនអរិយសច្ចៈ** ៖ ជាការរួចស្រឡះ ការរំលត់ទុក្ខ ហើយកន្លែងដែលរំលត់ទុក្ខគឺនិព្វាន។
- **មគ្គអរិយសច្ចៈ** ៖ ជាពុទ្ធិស្តីពីការយល់ដឹងអំពីមាគ៌ាប្រតិបត្តិ៨យ៉ាង «**អដ្ឋង្គិកមគ្គ**» ដើម្បីនាំខ្លួនឱ្យផុតទុក្ខ រំលត់ទុក្ខ ហើយទៅដល់ព្រះនិព្វាន។ ព្រះពុទ្ធអង្គទ្រង់បានពន្យល់ថា ត្រូវប្រកាន់យកផ្លូវកណ្តាល ហើយត្រូវប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវមគ្គៈទាំង៨គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាទៈ សម្មាកមន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ ។[6]

## ២.១.៥.ទស្សនៈកម្ម-ផល

ចំពោះទស្សនៈកម្ម-ផលវិញ គឺជាទស្សនៈសំខាន់បំផុតនៃលទ្ធិព្រះពុទ្ធសាសនា។ ពុទ្ធលទ្ធិបានពន្យល់ថា **កម្ម** ឬអំពើរបស់មនុស្ស សត្វដែលបានប្រព្រឹត្តហើយ ពុំរលាយសាបសូន្យទេ តែត្រូវនាំមកផលសម្រាប់សត្វដែលជាអ្នកប្រព្រឹត្ត ពោលគឺអ្នកធ្វើល្អតែងទទួលផលល្អ។ ឯអ្នកធ្វើអំពើអាក្រក់តែងតែទទួលផលអាក្រក់។ អំពើល្អនិងអំពើអាក្រក់ពុំអាចលុបលាង ឬទូទាត់គ្នាបានឡើយ។ បើបុគ្គលណាធ្វើអំពើល្អផងនិងអំពើអាក្រក់ផង ក៏ត្រូវតែទទួលផលល្អផងនិងផលអាក្រក់ផង។ កម្ម-ផលមិនសាបសូន្យឡើយ គ្រាន់តែយូរនិងឆាប់ប៉ុណ្ណោះ។ កម្មខ្លះត្រូវទទួលផលភ្លាមៗក្នុងបច្ចុប្បន្នជាតិ ឯកម្មខ្លះទៀតត្រូវទទួលផលក្នុងជាតិខាងមុខ។ ចំណែកកម្មខ្លះទៀតផ្តល់ផលក្នុងជាតិជាលំដាប់ៗទៅទៀត។ ទស្សនៈកម្ម-ផលនេះ ជាទស្សនៈមួយដ៏សំខាន់បំផុតនៃលទ្ធិព្រះពុទ្ធសាសនា ឬគេចាត់ទុកថាជាមូលដ្ឋានទ្រឹស្តីនៃសាសនាដែលធ្វើឱ្យមនុស្ស ជាពិសេសពុទ្ធសាសនិកជនទាំងឡាយខិតខំបំពេញអំពើកុសលធម៌ ពោលគឺអប់រំវាចា ចិត្ត និងសកម្មភាពឱ្យបានស្អាតផូរផង់។

---

[6] សកលចិន្តា គំនិតស្រាវជ្រាវដោយភិក្ខុធម្មបាល ខៀវ ជុំ ឆ្នាំ១៩៧២ ទំព័រទី៣៨ -៣៩

## ២.២.អំពីសីលធម៌និងចរិយាធម៌

### ២.២.១.និយមន័យសីលធម៌

ពាក្យ **សីលធម៌** គឺដំបូន្មានដែលនាំឱ្យចៀសវាងនូវអកុសល ហើយប្រព្រឹត្តតែកុសល។ សភាវៈពិតរបស់មនុស្សចូលចិត្តសេចក្ដីសុខ ស្អប់ខ្ពើមសេចក្ដីទុក្ខ មានទំនួលខុសត្រូវនិងមានហិរិ(សេចក្ដីខ្មាសបាប)និងឱត្តប្បៈ(សេចក្ដីខ្លាចបាប)។ ជាមួយគ្នានេះផងដែរ សីលធម៌ដែលមនុស្សត្រូវមានគឺ សីលធម៌ចំពោះខ្លួនឯង សីលធម៌ចំពោះគ្រួសារ សីលធម៌ចំពោះអ្នកដទៃ សីលធម៌នៅក្នុងវិជ្ជាជីវៈ និងសីលធម៌ចំពោះពិភពលោក។

### ២.២.២.និយមន័យចរិយាធម៌

ពាក្យ **ចរិយាធម៌** គឺជាការប្រព្រឹត្តត្រឹមត្រូវខាងផ្លូវកាយ វាចា និងចិត្ត។ ចរិយាធម៌ គឺសង្កត់ធ្ងន់ទៅលើគោលធម៌ប្រតិបត្តិហៅថា កល្យាណធម៌ ឬបញ្ចសីល ដែលជាធម៌បរិសុទ្ធ គ្រឿងតុបតែងរាងកាយមនុស្សឱ្យមានសម្រស់ផូរផង់ ពន្លឺចែងចាំង ក្លិនក្រអូបសុសសាយ មានកេរ្តិ៍ឈ្មោះពីរោះ រស់នៅសុខស្រួល។ ចរិយាធម៌ដែលមនុស្សត្រូវមានគឺ មេត្តា (គិតចង់ឱ្យគេបានសុខនិងករុណាចង់ឱ្យគេប្រាសចាកទុក្ខ) សម្មាអាជីវៈ (ចិញ្ចឹមជីវិតប្រពៃ) សទារសន្តោស (ត្រេកអរចំពោះភរិយាខ្លួន) សច្ចៈ (ប្រព្រឹត្តខ្លួនជាមនុស្សត្រង់) និងសតិ (មានស្មារតីបរិបូណ៌)។

## ជំពូក៣ បញ្ហាសីលធម៌និងចរិយាធម៌នៅក្នុងសង្គមខ្មែរ

### ៣.១.ការស្រុតចុះនៃតម្លៃសីលធម៌ក្នុងសង្គមខ្មែរ

ព្រះពុទ្ធបានសម្តែងថា អនិច្ចំ ទុក្ខំ អនត្តា។ អនិច្ចំ មានន័យថាមិនទៀងទាត់ អ្វីតែងតែប្រែប្រួល ហើយអ្វីៗដែលកើតឡើងហើយរមែងរលត់ផុតទៅវិញជាធម្មតា។ ទុក្ខំ ប្រែថាអ្វីដែលកើតឡើងមក ហើយរមែងមានទុក្ខជាប់មកជាមួយជានិច្ច។ អនត្តា ប្រែថាមិនមែនជារបស់ខ្លួន គ្មាននរណាម្នាក់អាច គ្រប់គ្រង ឬបញ្ជាទៅអ្វីមួយបានជារៀងរហូតឡើយ។ ឯសីលវិញក៏យ៉ាងនោះដែរ រមែងប្រែប្រួលជានិច្ច តែគ្មាននរណាដែលមិនត្រូវការសីលធម៌ទេ គ្រាន់តែពេលខ្លះគេមិនអាចបង្កើត ឬគ្រប់គ្រងវាឱ្យស្ថិតស្ថិរ ជានិរន្តរ៍តែប៉ុណ្ណោះ។ សព្វថ្ងៃ យើងសង្កេតឃើញមានកត្តាជាច្រើនដែលធ្វើឱ្យសីលធម៌ធ្លាក់ចុះគឺ៖

- **មនោសញ្ចេតនាបាក់ផ្លូវ** ៖ សកម្មភាពនេះភាគច្រើនកើតឡើងរវាងឪពុកម្តាយនិងកូន ព្រោះ ឪពុកម្តាយភាគច្រើនបង្រៀនកូនឱ្យចេះជេរ ឬក៏វាយក្បាលខ្លួន ហើយខ្លួនបែរជាសើចសប្បាយ ទៅវិញ។ ទាំងនេះហើយដែលធ្វើឱ្យកូនៗរឹតតែហ៊ានឡើងៗ។
- **ការបាត់បង់ជំនឿលើខ្លួនឯង** ៖ ការបរាជ័យលើការងារនិងគោលបំណងញឹកញាប់ ហើយគួប ផ្សំនឹងការមិនអាចគ្រប់គ្រងចិត្តខ្លួនឯងបាន ធ្វើឱ្យគេបាត់បង់ក្តីសង្ឃឹម គិតថាសង្គមអយុត្តិធម៌ ហើយមើលឃើញតែភាពខ្មៅងងឹតក្នុងជីវិត។ ពេលខ្លះគេលែងចង់រស់ ហើយពេលខ្លះលែងគិត ពីអ្នកជុំវិញខ្លួន រហូតសម្រេចចិត្តធ្វើសកម្មភាពផ្សេងៗដែលគេគិតថា ជាការទាមទារយុត្តិធម៌ពី សង្គមមកវិញ ហើយក៏អាចធ្លាក់ខ្លួនជាចោរ ជាឃាតករ ឬជាមនុស្សព្រៃផ្សៃ។
- **សង្គ្រាមអូសបន្លាយ** ៖ សង្គ្រាមញឹកញាប់និងអូសបន្លាយយូរពេកធ្វើឱ្យមនុស្សធ្លាក់នៅក្នុងភាព ក្រីក្រ ខ្វះជម្រក ព្រាត់ប្រាសបងប្អូន ប្រពន្ធប្តី ឪពុកម្តាយ លែងជឿទុកចិត្តគ្នា ខ្វះការអប់រំ ខ្វះ អាហារ។ល។ ពេលនោះធ្វើឱ្យមនុស្សលែងត្រូវការសេរីភាព លែងខ្វល់ពីសីលធម៌ គឺគេត្រូវការ តែដុំបាយដើម្បីចម្អែតក្រពះប៉ុណ្ណោះ។ នេះដូចទស្សនៈមួយពោលថា «សុភមង្គលរបស់អ្នកនឹង ផ្លោះចេញតាមបង្អួចនៅពេលដែលភាពក្រីក្របានមកដល់មាត់ទ្វាររបស់អ្នក»។
- **មហិច្ឆតា** ៖ ការលោភលន់របស់មនុស្ស គឺគ្មានទីបញ្ចប់ឡើយ ហើយនឹងបង្កើតឱ្យមានអ្នកមាន និងអ្នកក្រ ព្រមជាមួយនឹងភាពអយុត្តិធម៌ផងដែរ។ នេះដូចគេពោលថា «មនុស្សគឺជាឆ្កែចចក គឺគេមិនខ្លាចនឹងប្រព្រឹត្តអំពើផ្សេងៗដើម្បីបម្រើឱ្យផលប្រយោជន៍ខ្លួនគេឡើយ»។

- **ទ្រព្យសម្បត្តិ** ៖ ពេលមនុស្សមានសម្ភារៈនិងទ្រព្យសម្បត្តិហូរហៀរពេក គេលែងស្តាយនិងលែងខ្វល់ខ្វាយពីរបស់បន្តិចបន្តួចហើយ ព្រោះគិតថារបស់មួយដែលខូចទៅ អាចទិញថ្មីទៀតបាន។ ពេលនោះមនុស្សគិតថា មានប្រាក់គឺមានអ្វីៗទាំងអស់ ហើយប្រព្រឹត្តអំពើផ្សេងៗដើម្បីលុយ។
- **ការហូរចូលនៃវប្បធម៌បរទេស** ៖ ការប្រើប្រាស់សម្ភារៈទំនើបៗ ការចម្លងនូវរបៀបរស់នៅតាមរបៀបបរទេសដែលខុសពីសង្គមជាតិរបស់ខ្លួនបានធ្វើឱ្យសីលធម៌សង្គមជាតិបាត់បង់។ ពីមុនខ្មែរតែងរាក់ទាក់គ្នាដោយទឹកតែ តែឥឡូវភាគច្រើនទទួលរាក់ទាក់គ្នាដោយសុរា ឬគ្រឿងស្រវឹង ហើយការញ៉ាំគ្រឿងស្រវឹងនេះទៀតសោត អាចបង្កឱ្យមានមិត្ត តែក៏បង្កឱ្យមានជម្លោះផងដែរ។
- **ច្បាប់** ៖ ច្បាប់ត្រូវបានតាក់តែងឡើងដើម្បីកំណត់ពីសិទ្ធិសេរីភាពរបស់មនុស្សក្នុងសង្គម ដើម្បីឱ្យសង្គមមានសណ្តាប់ធ្នាប់ មានសីលធម៌ ប៉ុន្តែពេលខ្លះច្បាប់ក៏ត្រូវបានតាក់តែងឡើងដោយក្រុមមនុស្សអ្នកមានអំណាច ហើយគ្រប់គ្រងនិងជិះជាន់កៀបសង្កត់អ្នកទន់ខ្សោយ។ ច្បាប់មិនមានការលើកលែងទេ អ្នកធ្វើខុសត្រូវទទួលទោស។ ប៉ុន្តែបើច្បាប់មានប្រព័ន្ធពីរផ្សេងគ្នា នឹងធ្វើឱ្យមនុស្សកាន់តែគឃ្លើននិងហ៊ានធ្វើអំពើអបាយមុខផ្សេងៗដោយមិនខ្លាចទោសពៃ។
- **គ្រឿងញៀន** ៖ ការប្រើប្រាស់គ្រឿងញៀនធ្វើឱ្យមនុស្សវង្វេងស្មារតី លែងស្គាល់អ្វីល្អ អ្វីអាក្រក់ ហ៊ានធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីបំពេញបំណងខ្លួន។
- **ការអប់រំ** ៖ បុគ្គលដែលខ្វះការអប់រំ ខ្វះចំណេះដឹង ខ្វះការពិចារណា នោះនឹងធ្វើឱ្យគេមិនដឹងថាតើសកម្មភាពដែលគេបានធ្វើត្រឹមត្រូវទៅតាមគន្លងសីលធម៌ដែរឬអត់ទេ។ បើនៅតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជា បណ្តាញសង្គម ទូរទស្សន៍ វិទ្យុ និងទស្សនាវដ្តី បានប្រើប្រាស់នូវពាក្យសម្តីខ្វះនូវក្រមសីលធម៌ផងដែរ តែគេបែរជាគិតថាជាការលេងសើចសប្បាយទៅវិញ។

## ៣.២.ផលប៉ះពាល់នៃការធ្លាក់ចុះសីលធម៌

មានហេតុ ត្រូវមានផល នេះជាសច្ចធម៌ដែលសម្តែងឡើងដោយព្រះសម្មាសម្ពុទ្ធ។ ចំណែកឯសីលធម៌ក៏ដូច្នេះដែរ បើកាលណាសីលធម៌ដែលជាសេចក្តីល្អបានរុះរោយធ្លាក់ចុះហើយរមែងបាននូវលទ្ធផលអាក្រក់ ឬសេចក្តីអាក្រក់កើតឡើងដូចជា៖

- **ការបាត់បង់នូវសេចក្តីសុខខាងផ្លូវចិត្ត** ៖ តើសេចក្តីសុខនឹងកើតឡើងម្តេចបានទៅ បើខ្លួនយើងនិងសង្គមដែលយើងរស់នៅពោរពេញដោយក្តីអសប្បុរស គ្មានធម៌មេត្តាករុណានៅក្នុងខ្លួន មានតែភាពច្រណែនឈ្នានីស មានតែភាពលោភលន់។ ព្រះសាស្តាបានសម្តែងថា មានរូបគឺមានទុក្ខ សេចក្តីទុក្ខកើតមានឡើងដោយអវិជ្ជានិងតណ្ហា ឬលោភៈ ទោសៈ និងមោហៈ។ យើងនឹងមិនបានសុខទេ បើចិត្តរបស់យើងនៅតែចង់បានឥតឈប់ឈរ។
- **បាត់បង់គុណតម្លៃជាមនុស្ស** ៖ ដរាបណាមនុស្សគ្មានវិន័យ គ្មានច្បាប់ គ្មានសីលធម៌ក្នុងខ្លួន វាមិនខុសអ្វីពីសត្វធាតុដែលគ្មាននូវពិចារណញាណនោះទេ ហើយសង្គមនោះក៏មិនខុសពីសង្គម

សត្វដែរ។ ពួកគេលួច ឆក់ ប្លន់ កាប់សម្លាប់គ្នាដោយគ្មានញញើត ហើយចាត់ទុករឿងទាំងនេះជាល្បែងកម្សាន្តទៀតផង ដែលគេឱ្យនិយមន័យថា សន្ដានមនុស្សព្រៃ ឬសត្វតិរច្ឆាន។

- **បែកបាក់សាមគ្គី** ៖ យើងដឹងហើយថាសីលធម៌បានតាក់តែងមនុស្សឱ្យចេះរស់នៅជាមួយគ្នាដោយសេចក្ដីសុខ ប៉ុន្ដែបើពួកគេលែងមានសីលធម៌ លែងទុកចិត្តគ្នា នោះពួកគេនឹងព្យាយាមផ្ដាច់ខ្លួនចេញពីគ្នាដើម្បីស្វែងរកទីដែលគេគិតថាផ្ដល់សេចក្ដីសុខដល់ខ្លួនគេ។
- **អសន្តិសុខសង្គម** ៖ សង្គមដែលពោរពេញដោយចោរកម្ម មានអំពើហិង្សាផ្សេងៗ ដែលកើតឡើងដោយពួកមនុស្សល្ងង់ខ្លៅ អសីលធម៌ រួមផ្សំជាមួយនឹងប្រព័ន្ធច្បាប់ធូររលុង នោះសមាជិកនៅក្នុងសង្គមប្រាកដជាមិនអាចរស់នៅដោយសេចក្ដីសុខឡើយ គឺពួកគេប្រាកដជារស់នៅដោយភាពភ័យខ្លាចគ្រប់វិនាទី។
- **សង្គ្រាម** ៖ មហិច្ឆតាដែលគ្មានដែនកំណត់ រួមផ្សំនឹងគ្មានសីលធម៌គ្របដណ្ដប់នឹងបណ្ដាលឱ្យមានភាពច្រណែនគ្នា ចង់បានរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន ដូចដែលព្រះជិនស្រីសម្ដែងថា «ទោះបីមានភ្នំ មាសពីរក៏មិនស្មើល្មមគ្រប់គ្រាន់សម្រាប់តណ្ហារបស់មនុស្សម្នាក់ដែរ ប្រាកដជាទៅដណ្ដើមភ្នំមាសអ្នកដទៃមិនខាន»។ បើទីណាមានការគាបសង្កត់ មានការជិះជាន់ ទីនោះប្រាកដជាមានការរើបម្រាស់ គ្មានអ្នកណាម្នាក់អង្គុយឱ្យគេមកយករបស់ដែលជាទីស្រឡាញ់ដោយងាយៗ ឬអង្គុយចាំឱ្យគេមកជេរប្រមាថ កាប់សម្លាប់ដោយងាយៗនោះដែរ គេប្រាកដជាក្រោកបះបោរតស៊ូដល់ទីបញ្ចប់ ដែលធ្វើឱ្យសង្គ្រាមផ្ទុះឡើងគ្មានទីបញ្ចប់ដូចគ្នា។

## ៣.៣.ការលើកកម្ពស់សីលធម៌ក្នុងសង្គម

ដោយឈរលើទស្សនៈថា បញ្ហាអ្វីក៏មានដំណោះស្រាយ បញ្ហាអ្វីក៏អាចដោះស្រាយបាន។ យើងក៏អាចនិយាយបានថា សីលធម៌ដែលធ្លាក់ចុះនោះ វាក៏អាចស្រោចស្រង់មកវិញបានដែរ គឺយើងអាចស្រោចស្រង់ដោយមធ្យោបាយមួយចំនួនដូចជា៖

- **ផ្ដើមពីបុគ្គលខ្លួនឯង** ៖ ការស្គាល់ខ្លួនឯង ព្យាយាមគ្រប់គ្រងខ្លួនឯងជាបញ្ហាចម្បង នឹងធ្វើឱ្យយើងស្គាល់និងយល់ពីសន្ដានចិត្តរបស់អ្នកដទៃ។ ព្រះពុទ្ធបានសម្ដែងថា «បុគ្គលគ្រប់រូបត្រូវស្គាល់តួនាទីរបស់ខ្លួនឱ្យបានល្អប្រពៃតាមតួនាទី»។ នេះមានន័យថា យើងត្រូវធ្វើជាកូនល្អក្នុងគ្រួសារ សិស្សល្អក្នុងសាលារៀន ពលរដ្ឋល្អក្នុងសង្គម បុគ្គលិកល្អក្នុងអង្គភាព។
- **ការស្គាល់ពីគុណតម្លៃខ្លួនឯងនិងអ្នកដទៃ** ៖ មនុស្សត្រូវការការផ្ដល់តម្លៃ ការគោរពរាប់អាន ដូច្នេះបើខ្លួនយើងចង់ឱ្យអ្នកដទៃឱ្យតម្លៃវិជ្ជមានមកលើយើង គោរពស្រឡាញ់យើង លុះត្រាតែយើងឱ្យតម្លៃវិជ្ជមាននិងគោរពស្រឡាញ់អ្នកដទៃវិញដែរ។ នេះមានន័យថា បើចង់ឱ្យអ្នកដទៃធ្វើអំពើល្អមកលើយើង លុះត្រាតែយើងធ្វើអំពើល្អទៅគេផងដែរ។ បុគ្គលគ្រប់រូបត្រូវចេះជួយទុក្ខធុរៈគ្នា ស្មោះត្រង់ចំពោះគ្នានឹងគ្នា ចែករំលែកផលប្រយោជន៍គ្នាតាមសមគួរ មានទឹកចិត្ត

រីករាយជាប្រចាំ មានព្រហ្មវិហារធម៌ចំពោះគ្នាទៅវិញទៅមក ដោយយល់ថា បើចង់ឱ្យអ្នកដទៃគោរពខ្លួនយ៉ាងណា យើងត្រូវគោរពអ្នកដទៃយ៉ាងនោះដែរ។

- **លើកទឹកចិត្តសកម្មភាពសីលធម៌** ៖ គ្មានបុគ្គលណាមិនត្រូវការការកោតសរសើរនោះទេ ព្រោះមនុស្សត្រូវការការគោរពស្រឡាញ់និងការឱ្យតម្លៃលើកិត្តិយសផ្ទាល់ខ្លួន។ បើយើឱ្យតម្លៃខ្ពស់ និងលើកសរសើរដល់អ្នកដទៃដែលបានធ្វើនូវសកម្មភាពសីលធម៌នោះ ពួកគេនឹងព្យាយាមធ្វើសកម្មភាពទាំងនេះកាន់តែខ្លាំងឡើងៗ។ នេះដូចជាសកម្មភាពជួយទុក្ខធុរៈគ្នា ចែករំលែកនូវសម្ភារៈប្រើប្រាស់ ទ្រព្យសម្បត្តិ ចំណេះដឹងផ្សេងៗ យើងក៏គួរផ្ដល់ឱ្យពួកគេនូវរង្វាន់តាមអ្វីដែលពួកគេរីករាយនឹងទទួលបាន។ ព្រះពុទ្ធបានសម្ដែងថា «យើងត្រូវតបស្នងគុណដល់អ្នកដែលបានធ្វើគុណមកលើយើង»។ នេះជាកត្តាដែលធ្វើឱ្យមនុស្សចេះអធ្យាស្រ័យគ្នានិងធ្វើឱ្យសកម្មភាពសីលធម៌កាន់តែមានភាពរស់រវើកឡើង ហើយការគ្រប់គ្រងដោយសីលធម៌ គឺវាមានភាពប្រសើរជាងការគ្រប់គ្រងដោយច្បាប់ទៅទៀត។
- **បង្កើនការអប់រំផ្នែកសីលធម៌** ៖ បច្ចេកវិទ្យាកាន់តែខ្ពស់ នឹងធ្វើឱ្យមនុស្សកាត់បន្ថយជំនឿទៅលើសាសនាដែលធ្វើឱ្យមនុស្សមានសីលធម៌។ បើវិទ្យាសាស្ត្រគ្មានសីលធម៌ នោះសង្គមនឹងមានគ្រោះថ្នាក់។ សង្គមគួរយកចិត្តទុកដាក់អប់រំបង្រៀនមនុស្សដែលមិនបានដឹង បានស្គាល់ឱ្យបានដឹងនិងស្គាល់ ហើយយល់ពីតម្លៃរបស់សីលធម៌។ ឯការផ្សព្វផ្សាយតាមបណ្ដាញសង្គម វិទ្យុ ទូរទស្សន៍ក៏ជាកត្តារួមចំណែកដល់ការអប់រំផ្នែកសីលធម៌ដែរ។ យើងគួរផ្សព្វផ្សាយផ្នែកសីលធម៌និងប្រើប្រាស់នូវភាសាប្រកបដោយសីលធម៌ឱ្យបានច្រើន ជាជាងការជេរប្រទេចគ្នា ឬយកសីលធម៌ធ្វើជារឿងកំប្លែងសម្រាប់សើចកម្សាន្ត។
- **ការបណ្ដុះគំនិតជាតិនិយម** ៖ ជាតិនិយម ជាទ្រឹស្ដីអប់រំឱ្យស្រឡាញ់ជាតិ ស្រឡាញ់ប្រទេស ស្រឡាញ់ប្រវត្តិសាស្ត្រនិងមានគំនិតកសាងជាតិឱ្យទៅជារដ្ឋត្រឹមត្រូវនិងសម្បូរសប្បាយ។ ដ្បិតមនុស្សគ្រប់រូបមែងគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនក៏ពិតមែន តែបើគេមានជាតិនិយមក្នុងខ្លួន គេនឹងស្រឡាញ់សង្គមជាតិរបស់ខ្លួនគេ និងចង់ឱ្យពិភពលោកទាំងមូលរស់នៅក្នុងសន្តិភាព។
- **សន្តិភាពក្នុងចិត្ត** ៖ សន្តិភាពគឺសេចក្ដីស្ងប់ សេចក្ដីស្រឡាញ់ ចិត្តមេត្តាករុណា អធ្យាស្រ័យ និងគ្មានសង្គ្រាម។ ដើម្បីឱ្យមនុស្ស ឬសង្គមមានសន្តិភាពនិងអាចស្ថិតស្ថេរបានលុះត្រាតែមានការគោរពសិទ្ធិ អត់ឱន អធ្យាស្រ័យ និងទំនាក់ទំនងល្អជាមួយអ្នកដទៃ។
- **រឹតបន្តឹងច្បាប់** ៖ បើច្បាប់បង្កើតឡើងដោយប្រជាពលរដ្ឋនិងដើម្បីប្រជាពលរដ្ឋ នោះច្បាប់ត្រូវតែអនុវត្តន៍ទៅលើគ្រប់បុគ្គលទាំងអស់ដោយស្មើភាពគ្នា។ ប្រទេសមួយដែលរឹងមាំមានស្ថិរភាព មានការរីកចម្រើនគឺអាស្រ័យច្បាប់ ហើយច្បាប់ត្រូវតែមានសមភាពចំពោះប្រជាប្រជាពលរដ្ឋទាំងអស់។ កាលណាច្បាប់មិនមានភាពធូររលុងទេ នោះនឹងដាក់ទោសស្មើៗគ្នា ហើយមនុស្សនឹងខ្លាច មិនហ៊ានប្រព្រឹត្តិខុសច្បាប់សង្គមនិងសីលធម៌ឡើយ។

## ជំពូក៤ ពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌និងចរិយាធម៌

កាលពីដើម ពុទ្ធសាសនាមានប្រសិទ្ធភាពក្នុងការអប់រំ ព្រោះប្រជាជនភាគច្រើនជឿទុកចិត្តលើសាសនា។ អាស្រ័យហេតុនេះហើយ ទើបព្រះសង្ឃគ្រប់វត្តអារាមទាំងអស់តែងតែអប់រំផ្នែកទ្រឹស្តីនិងស្មារតី តាមរយៈការសម្តែងធម៌ទេសនានៅតាមវិទ្យុ ទូរទស្សន៍ និងគ្រប់តែពិធីបុណ្យនានា។ ដូចនេះព្រះពុទ្ធសាសនា គឺបានដើរតួនាទីសំខាន់ក្នុងការអប់រំ ផ្តល់ដំបូន្មានប្រកបដោយធម៌ ផ្តល់នូវមេត្តាធម៌ករុណា សន្តោសប្រណីតាមផ្លូវធម៌។

### ៤.១.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈបុណ្យទេសនាទសជាតក

បុណ្យទេសនាទសជាតក ជាបុណ្យសំខាន់មួយសម្រាប់អប់រំចរិយាសង្គមខ្មែរ។ បុណ្យនេះ គឺជាការសម្តែងចរិយាព្រះបរមពោធិសត្វ ដែលព្រះអង្គបំពេញទសបារមីក្នុងអតីតជាតិឱ្យបានត្រាស់ដឹងធម៌ ដើម្បីឱ្យប្រជាជនស្តាប់ ហើយយកជាគតិទុកជាពន្លឺក្នុងជីវិតគ្រប់ៗគ្នា សម្រាប់ប្រតិបត្តិយកសេចក្តីសុខនាលោកនេះនិងបរលោក។ អាស្រ័យដោយការអប់រំដ៏ប្រសើរនេះ ប្រជាជនខ្មែរបានចេះដឹងពុទ្ធចរិយាដែលព្រះអង្គបានខំអប់រំបន្ទុំបំពេញទសបារមីគ្រប់ជាតិ ហើយប្រព្រឹត្តតាមពុទ្ធចរិយា យកពុទ្ធចរិយានេះជាគតិប្រចាំជីវិតដើម្បីទូន្មានខ្លួនឱ្យប្រព្រឹត្តល្អ ឱ្យមានសីលធម៌ខ្ពង់ខ្ពស់ ឱ្យមានចិត្តតាំងនៅក្នុងធម៌។

ជនជាតិខ្មែរដែលបានខំកសាងខ្លួនតាមពុទ្ធចរិយានេះ គឺបានផលល្អណាស់ ដោយបានកើតទៅជាអរិយជននៃប្រជាជាតិមួយដ៏ប្រសើរក្នុងលោកនេះ។ តាំងពីបុរាណកាលមកជនជាតិខ្មែរ មានកាយវាចាចិត្តសុភាពរាបសា មិនឆ្មើងកន្ត្រើងទេ កាយទន់ភ្លន់ ចេះឱនលំទោនគោរពចាស់ព្រឹទ្ធាចារ្យត្រកូលរៀមច្បង ចេះគោរពកោតក្រែងគ្នាទៅវិញទៅមក មិនប្រឡោះបោះប្រឡោងខាមទេ វាចាពីរោះចេះនិយាយគួរសមដឹងទាបខ្ពស់ មិនសូវនិយាយពាក្យទ្រគោះបោះបោកទៅកាន់អ្នកដទៃទេ ចិត្តល្អកាន់សច្ចៈធម៌ទៀងត្រង់ ហើយស្លូតបូត មិនសូវចេះបៀតបៀនអ្នកដទៃ មិនសូវទាស់ទែងគ្នាទេ មានសាមគ្គីធម៌ហើយចេះស្តាប់បង្គាប់មេបាណាស់។ នេះហើយជាវប្បធម៌ដ៏ប្រសើរ ដែលបុព្វបុរសខ្មែរបានកសាងទុកជាកេរ្តិ៍តំកឱ្យជនជាតិខ្មែរ ដើម្បីទុកឱ្យជនជាតិខ្មែរមានវប្បធម៌ល្អប្រសើរ។

### ៤.២.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈសីល៥

គ្រួសារមួយ សង្គមមួយ ប្រទេសជាតិមួយ រហូតដល់ពិភពលោកទាំងមូលនឹងគ្មានសន្តិភាពឡើយ ប្រសិនបើមនុស្សប្រាសចាកសីលធម៌ទាំង៥ប្រការ។ សីលធម៌៥យ៉ាងនេះ ថ្វីដ្បិតតែជាពុទ្ធឱវាទក៏ពិតមែន តែជាសីលធម៌សាកលសម្រាប់មនុស្សគ្រប់រូបនៅក្នុងលោក ប្រតិបត្តិដើម្បីសុខសន្តិភាព។

- **បាណាតិបាតា វេរមណី** ៖ ការមិនសម្លាប់បៀតបៀនជីវិតអ្នកដទៃ ដោយចៀសវាងដាច់ខាតនូវការកាប់សម្លាប់ ជិះជាន់ បៀតបៀនជីវិតអ្នកដទៃ។ ជីវិតកើតមកតែងតែប្រាថ្នាចង់រស់នៅក្នុង

ភាពសុខសាន្តនិងការជួបជុំគ្រួសារ គ្មានអ្នកណាម្នាក់ចង់ឱ្យមនុស្សដែលខ្លួនស្រឡាញ់ត្រូវបាត់បង់ជីវិត និរាសព្រាត់ប្រាស់ពីខ្លួន ដោយសារការបៀតបៀនពីអ្នកដទៃឡើយ។

- **អទិន្នាទានា វេរមណី** ៖ ការមិនលួចឆក់ទ្រព្យអ្នកដទៃ ដោយវៀរចាកការលួចឆក់ទ្រព្យសម្បត្តិមាសប្រាក់ដែលមានម្ចាស់ថែរក្សា។ យើងមិនត្រូវសម្លុតគំរាមកំហែង ឬបង្ខិតបង្ខំដើម្បីអូសយកដីផ្ទះសម្បែងគេនោះទេ។
- **កាមេសុ មិច្ឆាចារា វេរមណី** ៖ ការមិនប្រព្រឹត្តខុសក្នុងកាម ដោយមិនប្រព្រឹត្តខុសក្នុងផ្លូវកាមលើសាច់ញាតិអ្នកដទៃ។ យើងស្រឡាញ់ហួងហែងកូន ប្រពន្ធ ប្ដីសាច់ញាតិ និងមនុស្សដែលយើងស្រឡាញ់យ៉ាងណា អ្នកដទៃគេក៏ស្រឡាញ់ហួងហែងកូនប្រពន្ធ ប្ដី សាច់ញាតិ និងមនុស្សដែលគេស្រឡាញ់យ៉ាងនោះដែរ។ ទាំងយើងទាំងគេ តែងតែប្រាថ្នាចង់ឱ្យស្វាមីភរិយា បុត្រាបុត្រី រស់នៅដោយសុភមង្គល មិនចង់ឱ្យអ្នកណាមករំលោភបំពានលើក្រុមគ្រួសារខ្លួនឡើយ។
- **មុសាវាទា វេរមណី** ៖ ការមិនកុហកអ្នកដទៃ ត្រូវប្រកាន់ខ្ជាប់នូវពាក្យសច្ចៈ ដោយចៀសវាងការកុហកបោកប្រាស់អ្នកដទៃ។ ការកុហកជាហេតុនាំមកនូវការបាត់បង់តម្លៃ បើកុហកគេម្ដងគេលែងជឿមួយជីវិត។ ពេលខ្លះគេអាចនឹងអធ្យាស្រ័យឱ្យ តែគេនឹងមិនភ្លេចពីទង្វើបោកប្រាស់និងពាក្យកុហករបស់យើងឡើយ។
- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** ៖ ការមិនសេពគ្រឿងញៀននិងគ្រឿងស្រវឹង ព្រោះជាហេតុនាំឱ្យស្មារតីប្រែប្រួល ហើយអាចប្រព្រឹត្តអំពើអកុសលនិងទង្វើមិនគប្បីផ្សេងៗ។

## ៤.៣.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈព្រហ្មវិហារធម៌

ព្រះពុទ្ធសាសនាតែងទូន្មានប្រៀនប្រដៅឱ្យមនុស្សគ្រប់គ្នាប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ទាំង៤ ដែលជាធម៌ដ៏ប្រសើរ ធម៌ដ៏បរិសុទ្ធ ដែលបានអប់រំចិត្តមនុស្សឱ្យមានក្ដីសុខ ព្រមទាំងអប់រំការប្រព្រឹត្តិរបស់មនុស្សឱ្យដើរលើគន្លងសីលធម៌ដ៏ថ្លៃថ្នូរ។

- **មេត្តា** ៖ ជាសេចក្ដីល្អ សេចក្ដីស្រឡាញ់ ការរាប់អាន និងចង់ឱ្យអ្នកដទៃបានសុខ។
- **ករុណា** ៖ ជាសេចក្ដីសន្ដោស អាណិតអាសូរ និងការជួយសម្រាលទុក្ខលំបាកអ្នកណាម្នាក់។
- **មុទិតា** ៖ ជាសេចក្ដីអំណរ ឬការសម្ដែងក្ដីរីករាយអស់ពីចិត្តចំពោះមនុស្សនៅជុំវិញ។
- **ឧបេក្ខា** ៖ ជាការតាំងចិត្តជាកណ្ដាល មិនលម្អៀង មិនគេចវេះ និងមានចិត្តស្មោះត្រង់។

## ៤.៤.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈគោលធម៌៨យ៉ាង

មនុស្សយើងប្រសិនបើមានគោលធម៌ទាំង៨ នោះនឹងនាំទៅរកសុភមង្គល រស់នៅដោយភាពថ្លៃថ្នូរ ព្រមទាំងពេញព្រៀបទៅដោយសីលធម៌និងចរិយាធម៌ដ៏ប្រពៃ។

- **សម្មាទិដ្ឋិ** ៖ ការយល់ឃើញនូវផ្លូវល្អ ត្រឹមត្រូវ
- **សម្មាសង្កប្ប** ៖ ការប្រកបភារកិច្ច ឬកិច្ចការដែលត្រឹមត្រូវ
- **សម្មាវាចា** ៖ ការប្រើពាក្យសម្តីល្អត្រឹមត្រូវ សុភាពរាបសា រួសរាយរាក់ទាក់
- **សម្មាកម្មន្ត** ៖ ការប្រកបការងារល្អត្រឹមត្រូវ
- **សម្មាអាជីវ** ៖ ការចិញ្ចឹមជីវិតដ៏ត្រឹមត្រូវ
- **សម្មាវាយាម** ៖ ការព្យាយាមត្រឹមត្រូវ
- **សម្មាសតិ** ៖ មានសតិ ការនឹករឭកដ៏ត្រឹមត្រូវ
- **សម្មាសមាធិ** ៖ ការតាំងចិត្ត ការធ្វើចិត្តឱ្យស្ងប់ល្អត្រឹមត្រូវបំផុត។

## ៤.៥.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈអំពើល្អ១០យ៉ាង

ព្រះពុទ្ធអំពើល្អ១០យ៉ាងនេះ ត្រូវបានព្រះពុទ្ធបរមគ្រូចាត់ទុកថា ជាគោលការណ៍គ្រឹះ ឬជាឫសគល់នៃធម្មទាំងឡាយនៃពុទ្ធសាសនាក្នុងការស្វែងរកសុខសន្តិភាព សុវត្ថិភាព សេចក្តីថ្លៃថ្នូរ កិត្តិយស និងការអភិវឌ្ឍន៍ដល់បុគ្គលខ្លួនឯងវង្ស់គ្រួសារនិងសង្គមជាតិទាំងមូល។

### ៤.៥.១.អំពើប្រព្រឹត្តល្អដោយកាយ៣ (កាយសុចរិត)

- ការវៀរចាកអំពើកាប់សម្លាប់ មនុស្ស ឬសត្វមានជីវិត
- ការមិនគេងបន្លំយកទ្រព្យសម្បត្តិរបស់អ្នកដទៃ
- ការមិនប្រព្រឹត្តខុសក្នុងកាម។

### ៤.៥.២.អំពើប្រព្រឹត្តល្អដោយវាចា៤ (វិចីសុចរិត)

- វៀរចាកនូវការមិនពោលពាក្យកុហកបោកប្រាសបំភាន់ភ្នែកអ្នកដទៃ
- ការមិនពោលនូវពាក្យញុះញង់ បំបែកបំបាក់អ្នកដទៃ
- ការនិយាយតែពាក្យផ្អែមល្ហែមទន់ភ្លន់ពិរោះ
- ការនិយាយអំពីប្រយោជន៍និងសេចក្តីចម្រើនទាំងពីប្រការគឺផ្លូវលោកមួយ ផ្លូវធម៌មួយ។

### ៤.៥.៣.អំពើប្រព្រឹត្តល្អដោយចិត្ត៣ (មនោសុចរិត)

- មិនតាំងចិត្តគិតសម្លឹងរំពៃយកទ្រព្យអ្នកដទៃមកជាទ្រព្យរបស់របស់ខ្លួន។
- មិនចងគំនុំគុំគួនធ្វើឱ្យអ្នកដទៃវិនាសនិងមិនបៀតបៀនអ្នកដទៃ។
- សេចក្តីយល់ឃើញត្រូវ គឺឃើញថាធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប។

## ៤.៦.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈក្រមសីលធម៌ទាំង៥

សង្គមមួយរីកចម្រើននិងមានសន្តិភាពក៏ដោយសារតែមនុស្សចេះជួយគ្នាទៅវិញទៅមក ហើយស្គាល់ពីតួនាទីរៀងៗខ្លួន។ មិនថានៅទីណា កន្លែងណានោះទេ សីលធម៌ជាមាគ៌ាដ៏ចម្បងសម្រាប់បំភ្លឺផ្លូវឱ្យជីវិត ហើយជីវិតដែលអាចរស់នៅសុខសាន្តត្រូវតែមានក្រមសីលធម៌ទាំង៥គឺៈ

### ៤.៦.១.សីលធម៌ផ្ទាល់ខ្លួន

ប្រជាពលរដ្ឋគ្រប់ត្រូវមានជាចាំបាច់និងស្គាល់ច្បាស់ពីសីលធម៌ផ្ទាល់ខ្លួន ទើបអាចជួយខ្លួនឯងឱ្យក្លាយជាមនុស្សមានតម្លៃនៅក្នុងសង្គម។ ករណីនេះ ពលរដ្ឋគ្រប់ត្រូវប្រកាន់សីលធម៌ចំពោះខ្លួនឯង ហើយធ្វើជាមនុស្សដឹងខុសដឹងត្រូវ ស្គាល់ល្អ ស្គាល់អាក្រក់ តាំងខ្លួនជាម្ចាស់ចិត្តរបស់ខ្លួនឯង ទទួលខុសត្រូវនឹងអំពើរបស់ខ្លួន ក្លាហានក្នុងផ្លូវត្រូវជាដើម។

### ៤.៦.២.សីលធម៌ក្នុងគ្រួសារ

ករណីនេះ ពលរដ្ឋគ្រប់ត្រូវដឹងថា ប្រសិនបើខ្លួនជាអ្នកគ្រប់គ្រងគ្រួសារ ដូចជាឪពុកម្ដាយជាដើមនោះត្រូវ ចិញ្ចឹមកូន និងទំនុកបម្រុងកូនឱ្យបានសិក្សារៀនសូត្រ ត្រូវស្រឡាញ់កូនឲ្យបានស្មើភាពគ្នា ព្យាយាមធ្វើឱ្យគ្រួសារមានសុខដុម រៀបចំកូនឱ្យបានទៅជាពលលរដ្ឋពេញលេញ ព្រមទាំងរៀបចំកូនឲ្យមានគូក្រសរ និងទ្រព្យសម្បត្តិឱ្យកូនបានសមរម្យតាមលទ្ធភាពដែលខ្លួនមាន។ ការបំពេញបែបនេះ បង្ហាញឱ្យឃើញថា ឪពុកម្ដាយបានបំពេញសីលធម៌ក្នុងនាមខ្លួនជាអ្នកគ្រប់គ្រងគ្រួសារ។

### ៤.៦.៣.សីលធម៌ក្នុងវិជ្ជាជីវៈ

ការរស់នៅក្នុងសង្គម តម្លៃមួយដែលសំខាន់សម្រាប់មនុស្សគ្រប់រូបផងនោះ គឺតម្លៃវិជ្ជាជីវៈ។ ដើម្បីឱ្យទទួលបានតម្លៃនេះ បុគ្គលទាំងនោះត្រូវស្គាល់ពីសីលធម៌វិជ្ជាជីវៈ ដែលជាមូលដ្ឋាននាំឱ្យខ្លួនជាបុគ្គលមួយរូបមានតម្លៃចំពោះអាជីពរបស់ខ្លួន។ ចំណុចនេះ បុគ្គលគ្រប់រូបយ៉ាងហោចណាស់ ត្រូវមានមនសិការការងារ ព្យាយាមរកស៊ីតាមសមត្ថភាព រកស៊ីតាមសមាជីវោ មិនរំលោភលើអ្នកតូចជាងខ្លួន ព្រមទាំងធ្វើការហួសកម្លាំងខ្លួន នាំឱ្យមានជំងឺបាក់កម្លាំងកាយជាដើម។

### ៤.៦.៤.សីលធម៌ក្នុងសង្គម

ជាបុគ្គលម្នាក់ មិនមែនរស់នៅដោយគ្មានទំនាក់ទំនង គ្មានមិត្តភាពបាននោះទេ។ ហេតុនេះ ការអាចយល់និងប្រតិបត្តិបានសីលធម៌ក្នុងសង្គម គឺកិច្ចការចាំបាច់របស់បុគ្គលគ្រប់រូប។ ប្រការនេះ បុគ្គលគ្រប់រូបត្រូវស្គាល់ថា តម្លៃសីលធម៌ក្នុងសង្គមគឺ ការមិនបែកបាក់គ្នា មិនមើលងាយមនុស្សផងគ្នា ជាបុគ្គលស្រឡាញ់យុត្តិធម៌ ចេះរាប់អានមនុស្សទូទៅ ទទួលស្គាល់ទុក្ខវេទនារបស់អ្នកដទៃ ព្រមទាំង មិនរំលោភឈ្លានពានអ្នកដទៃជាដើម។

### ៤.៦.៥.សីលធម៌ក្នុងពិភពលោក

ការស្គាល់នូវសីលធម៌មួយនេះនឹងជួយបុគ្គលឱ្យចេះរួមរស់ដោយសន្តិភាពជាមួយប្រទេសដទៃ ទៅតាមគោលការណ៍របស់អង្គការសហប្រជាជាតិ ជាពិសេសលក្ខខណ្ឌ ដែលអង្គការសហប្រជាជាតិ បានកំណត់នៅទីក្រុងបានឌុងនាប្រទេសឥណ្ឌូនេស៊ី។

## ៤.៧.ការអប់រំសីលធម៌និងចរិយាធម៌ តាមរយៈការដឹងពីតួនាទី

ព្រះពុទ្ធបានសម្តែងថា «បុគ្គលគ្រប់រូបត្រូវស្គាល់តួនាទីរបស់ខ្លួនឱ្យបានល្អប្រពៃតាមតួនាទី»។ ហើយធម៌ព្រះពុទ្ធជាគន្លង ធម៌ព្រះពុទ្ធជាផ្លូវដ៏សំខាន់ សម្រាប់អប់រំកាយ វាចា ចិត្ត និងបណ្តុះបណ្តាល មនុស្សឱ្យកើតមាន មេត្តា ករុណា ប្រាសចាក លោភៈ ទោសៈ មោហៈ ដើម្បីជួយមនុស្សឱ្យរួចចាកផុត ពីសេចក្តីទុក្ខ ទៅរកសុខសន្តិភាពពិតប្រាកដ។ ព្រះពុទ្ធទ្រង់បានសម្តែងអំពីសង្គហធម៌ និងតួនាទីមាតា បិតានិងបុត្រធីតា រវាងគ្រូនិងសិស្ស រវាងស្វាមីនិងភរិយា រវាងមិត្តនិងមិត្ត រវាងនិយោជិតនិងនិយោជក រវាងអ្នកគ្រប់គ្រងនិងប្រជារាស្ត្រ រវាងភិក្ខុសង្ឃនិងឧបាសក ឧបាសិកាជាដើម។ ជាទូទៅតាមរយៈការ ឱ្យឱវាទរបស់ព្រះពុទ្ធសាសនា បានធ្វើឱ្យប្រជាជនកម្ពុជាមានសីលធម៌ គុណធម៌ មានសមានចិត្ត ទូលាយ រួសរាយរាក់ទាក់ មានចិត្តសប្បុរស មានសុជីវធម៌ មានចិត្តគំនិតទន់ភ្លន់ ស្លូតបូត សុភាព រាបសារ សច្ចៈទៀងត្រង់ ខ្លាចបុណ្យ ខ្លាចបាប ស្គាល់គុណនិងទោស មានចិត្តសន្តោសអធ្យាស្រ័យ ចេះ ជួយយកអាសារ មានសទ្ធាជ្រះថ្លាក្នុងកុសលធម៌ ពោលគឺជាអម្បូរមនុស្សដែលប្រកបដោយគុណធម៌។

### ៤.៧.១.តួនាទីមាតាបិតា

- មាតាបិតាគប្បីហាមកូនឱ្យវៀរអំពើបាប អំពើអាក្រក់នានា
- ញ៉ាំងកូនឱ្យតម្កល់នៅក្នុងកុសលធម៌ រៀនប្រព្រឹត្តអំពើសុចរិតតាមគន្លងធម៌
- គប្បីអប់រំកូនឱ្យពេញចិត្តក្នុងការសិក្សារៀនសូត្រ

- រៀបចំគូស្រករទៅតាមប្រពៃណី
- ចែកទ្រព្យសម្បត្តិឱ្យជាដើមទុន។

**៤.៧.២.តួនាទីកូន**

- ត្រូវចិញ្ចឹមបីបាច់ថែរក្សាមាតាបិតា ដើម្បីជាការដឹងគុណ
- ជួយធ្វើការដែលមាតាបិតាត្រូវការ
- រក្សាកេរ្តិ៍ឈ្មោះលើកតម្កើងពូជពង្សវង្សត្រកូល
- បម្រើមាតាបិតាដោយសុចរិតអោនលំទោន
- ត្រូវធ្វើបុណ្យឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោក។

**៤.៧.៣.តួនាទីស្វាមី**

- ពោលពាក្យពីរោះសរសើរដល់ភរិយា
- មិនមើលងាយ ជេរវាយភរិយា ដូចទាសា ទាសី កម្មករឡើយ
- មិនប្រព្រឹត្តកន្លងភរិយា មិនត្រូវប្រព្រឹត្តគំនិតក្បត់
- ប្រគល់នូវរបស់របរទាំងពួងឱ្យមានឥស្សរភាពដល់ភរិយា
- ស្វាមីគប្បីរៀបចំឱ្យមានអលង្ការដល់ភរិយាសម្រាប់ប្រើប្រាស់គ្រប់គ្រាន់។

**៤.៧.៤.តួនាទីភរិយា**

- ចាត់ចែងការងារផ្ទះដោយផ្ចិតផ្ចង់
- សង្គ្រោះញាតិខាងស្វាមីនិងខាងខ្លួនឯងដោយប្រពៃ
- គប្បីថែទាំទ្រព្យសម្បត្តិដែលប្ដីរកបានមិនឱ្យវិនាសខូចខាត
- មិនប្រព្រឹត្តកន្លងចិត្តប្ដី ឬក្បត់ប្ដី
- មិនត្រូវខ្ជិលច្រអូស។

**៤.៧.៥.តួនាទីគ្រូបាអាចារ្យ**

- ដឹកនាំសិស្សឱ្យល្អដោយសុទ្ធចិត្ត ដើម្បីឱ្យចេះប្រើឥរិយាបទទាំង ៤ គឺដេក ដើរ ឈរ អង្គុយ
- បង្ហាត់បង្រៀនសិស្សដោយល្អ
- គ្រូអាចារ្យគប្បីបង្ហាត់សិល្បៈវិទ្យាឱ្យអស់ចំណេះ
- លើកតម្កើងសិស្សក្នុងទីប្រជុំ
- ធ្វើសេចក្ដីការពារសិស្សគ្រប់ទិសទាំងឡាយ។

**៤.៧.៦.តួនាទីសិស្ស៥យ៉ាង**

- ក្រោកឈរទទួលក្នុងវេលាដែលគ្រូបាអាចារ្យដើរមក
- គាល់បម្រើគ្រូអាចារ្យដោយចិត្តស្មោះស
- ជឿស្តាប់ឱវាទលោកទូន្មានប្រៀនប្រដៅ
- ប្រណិប័តន៍ដោយធ្វើការងារជួយគ្រូអាចារ្យ
- ត្រូវរៀនសិល្បវិជ្ជាអំពីលោកគ្រូអាចារ្យដោយសេចក្តីគោរព។

**៤.៧.៧.តួនាទីចៅហ្វាយនាយ**

- ចាត់ចែងការងារឱ្យធ្វើតាមសមគួរ
- ឱ្យភោជនាហារនិងថ្លៃឈ្នួលដោយត្រឹមត្រូវដល់អ្នកបម្រើ
- ព្យាបាលក្នុងវេលាមានជំងឺ
- ចែកភោជនាហារដែលមានឱជារសប្លែកៗឱ្យបរិភោគ
- បើកឱ្យសប្បាយក្នុងការគួរ។

**៤.៧.៨.តួនាទីទាសកម្មករឬអ្នកបម្រើ**

- ក្រោកឡើងធ្វើការមុនចៅហ្វាយនាយ
- លែងធ្វើការងារក្រោយចៅហ្វាយនាយ
- កាន់យកតែរបស់ណាដែលចៅហ្វាយនាយឱ្យប៉ុណ្ណោះ
- ធ្វើការងារដោយយកចិត្តទុកដាក់ ពោលគឺធ្វើការងារឱ្យបានល្អ
- នាំកិត្តិគុណចៅហ្វាយនាយទៅពោលសរសើរក្នុងទីដទៃ។

**៤.៧.៩.តួនាទីមិត្តល្អ**

- ឱ្យអ្វីដែលគួរឱ្យដល់មិត្តសម្លាញ់
- និយាយពិរោះ មិនទ្រគោះគម្រោះគម្រើយ
- ត្រូវធ្វើប្រយោជន៍ដល់មិត្ត
- ត្រូវសង្គ្រោះមិត្តសម្លាញ់ដោយមិនលើកតម្កើងខ្លួន
- មិននិយាយបោកបញ្ឆោត ដោយការនិយាយកុហក។

## ៤.៨.គុណតម្លៃនៃព្រះពុទ្ធសាសនា

### ៤.៨.១.ប្រយោជន៍ចំពោះបុគ្គល

យើងដឹងហើយថា សាសនាជាអ្នកជួយសាងឧបនិស្ស័យចិត្តគំនិតមនុស្ស ជួយផ្តល់ចម្លើយដល់ជីវិត និងគោលការណ៍នៃដំណើរជីវិត។ សាសនាក៏ជួយឃុំគ្រងការប្រព្រឹត្តិបាបកម្មរបស់មនុស្សផងដែរ ហើយក៏ជាបច្ច័យមួយដែលជួយឱ្យបុគ្គលមានសេចក្តីសុខស្ងប់ខាងផ្លូវចិត្តនឹងធឹង ធ្វើឱ្យបុគ្គលមានសុខភាពចិត្តល្អរឹងមាំ នឹងនាំឱ្យមកនូវសុខភាពផ្លូវកាយល្អ ព្រោះសុខភាពរាងកាយអាស្រ័យលើសុខភាពផ្លូវចិត្ត។ សាសនាធ្វើឱ្យបុគ្គលមានអារម្មណ៍ល្អ មានសតិរឹងមាំជានិច្ច ប្រាសចាកការភ័យខ្លាច និងវិបត្តិទាំងឡាយទាំងពួង។ សាសនាជួយផ្តល់កម្លាំងចិត្ត ធ្វើឱ្យមនុស្សមានកម្លាំងចិត្ត ជឿជាក់លើខ្លួនឯងថាមានអ្នកជួយតាមថែរក្សាជានិច្ច ហើយក៏ជាបច្ច័យមួយដែលជួយឱ្យការធ្វើការងារបានសម្រេចនិងមានឱកាសយកឈ្នះឧបសគ្គនានា។ សាសនាជាបច្ច័យជួយឱ្យការចិញ្ចឹមជីវិតកាន់តែមានរបៀប មានវិន័យ និងមានគុណភាពល្អឡើង ហើយមានឱកាសជួបនូវក្តីសម្រេចនិងជួយអភិវឌ្ឍមនុស្សផងដែរ។

### ៤.៨.២.ប្រយោជន៍ចំពោះសង្គម

បើនិយាយពីតួនាទីសាសនាចំពោះសង្គម យើងសង្កេតជាទូទៅឃើញថា សាសនាមានតួនាទីសំខាន់ក្នុងការការពារនិងកំណត់សីលធម៌សង្គម។ សាសនាជាកម្លាំងជួយចាត់ចែងពីរបៀបវិន័យនិងសីលធម៌សង្គមដោយសមាជិករបស់សង្គម។ សាសនាធ្វើឱ្យមនុស្សប្រតិបត្តិតាមគោលធម៌ តាមឱវាទការអប់រំរបស់សាសនាដែលបានណែនាំឱ្យបដិបត្តិ។ សាសនាជាស្ថាប័នសាងតម្លៃនិយម បទដ្ឋានសង្គម និងជួយឱ្យស្ថាប័នគ្រួសារ ក៏ដូចជាស្ថាប័នគ្រប់គ្រងបំពេញតួនាទីរួមគ្នាយ៉ាងរឹងមាំ។ សាសនាបានជួយបណ្តុះគ្រឹះនៃសេចក្តីចម្រើនដល់សង្គម ដូចជាការផ្តល់នូវការសិក្សាអប់រំវិជ្ជាជីវៈខាងសុជីវធម៌ សីលធម៌ សុខាភិបាល និងការគ្រប់គ្រងជាដើម។ សាសនាក៏ចូលរួមចំណែកនៅក្នុងការជួយលើកស្ទួយសង្គមឱ្យមានភាពរឹងមាំ ជួយកាត់បន្ថយនិងកំចាត់បញ្ហាសង្គម ជួយឱ្យមានការគ្រប់គ្រងមានភាពងាយស្រួលដោយសារតែពលរដ្ឋបដិបត្តិតាមគោលធម៌របស់សាសនា។ ដូច្នេះសាសនាមានតួនាទីក្នុងការចងភ្ជាប់សង្គមឱ្យក្លាយជាផ្លុងមួយ មានភាពសាមគ្គីដោយសមាជិកប្រកាន់យក ឬបដិបត្តិតាមគោលធម៌ គឺឱវាទរបស់សាសនាដូចគ្នា ធ្វើឱ្យពលរដ្ឋក្នុងសង្គមរួមសាមគ្គីគ្នាយ៉ាងស្អិតរមួត។ ម៉្យាងទៀត គ្រប់សាសនាកើតឡើងក្នុងគោលបំណង គឺសេចក្តីសុខ សន្តិភាព កម្ចាត់ទុក្ខភ័យឱ្យប្រជាជន ទើបធ្វើឱ្យសង្គមអាចរួមរស់ជាមួយគ្នាបានដោយភាពសុខសាន្ត ភាពសុខដុមរមនា និងជួយអភិវឌ្ឍសង្គមដែលស្ថិតក្នុងពិភពលោកទាំងមូល។

# ជំពូក៥ សេចក្តីសន្និដ្ឋាននិងអនុសាសន៍

ឆ្លងតាមរយៈការស្រាវជ្រាវនិងវិភាគល្អិតល្អន់អំពីខ្លឹមសារពុទ្ធសាសនាក្នុងការអប់រំសីលធម៌និងចរិយាធម៌រួចមក យើងសង្កេតឃើញថា ទ្រឹស្តីនៅក្នុងព្រះពុទ្ធសាសនាគឺពិតជាបានរួមចំណែកយ៉ាងខ្លាំងក្នុងការអប់រំសីលធម៌និងការរស់នៅប្រចាំថ្ងៃឱ្យមានភាពថ្លៃថ្នូរនិងសន្តិភាព។ ហើយម្យ៉ាងវិញទៀតវត្តអារាមក៏ជាកន្លែងមួយសម្រាប់ផ្សះផ្សាផ្លូវចិត្តឱ្យមានសន្តិភាពផងដែរ។

ជាក់ស្តែង ព្រះពុទ្ធសាសនាតែងតែអប់រំទូន្មានប្រៀនប្រដៅឱ្យដើរលើផ្លូវត្រូវ វៀរចាកអំពើបាបហើយឱ្យខិតខំសន្សំអំពើល្អទៅដល់មនុស្សជុំវិញខ្លួន។ ពុទ្ធឱវាទក៏តែងតែហាមប្រាមមិនឱ្យបៀតបៀនអ្នកដទៃ ត្រូវរស់នៅជាមួយអំពើកុសល ញុំាំចិត្តឱ្យបរិសុទ្ធ ហើយចេះប្រើវាចាដោយទន់ភ្លន់ មិនទ្រគោះបោះបោក និងស្រឡាញ់រាប់អានគ្នាជាភារតភាព។ ពិសេសគឺបានធ្វើឱ្យសមាជិកគ្រួសារក្នុងសង្គមខ្មែរប្រកាន់យកជានិច្ចនូវសីលធម៌ល្អ ធ្វើអ្វីៗដោយអំណត់ព្យាយាម សុចរិត ទៀងត្រង់ សុភាពរាបសា មានសាមគ្គីភាព និងដឹងសុខទុក្ខគ្នា ព្រមទាំងចេះជួយទៅវិញទៅមក។ ហើយការជួយគ្នានេះទៀតសោត វាជាតម្លៃសីលធម៌ពិតរបស់មនុស្សគ្រប់រូប ព្រោះមនុស្សម្នាក់មិនអាចរស់នៅតែម្នាក់ឯងបានឡើយហើយក៏មិនត្រូវលិចលង់ក្នុងភាពអាត្មានិយមបានដែរ។

ដូច្នេះក្នុងនាមយើងជាប្រជាជនខ្មែរមួយ និងជាពុទ្ធសាសនិកមួយ គប្បីគោរពនិងប្រតិបត្តិទ្រឹស្តីនិងវិន័យល្អៗក្នុងព្រះពុទ្ធសាសនា ដើម្បីក្លាយជាមនុស្សថ្លៃថ្នូរ ប្រកបដោយសុភាវធម៌ពិត រួមមានសុជីវធម៌ សីលធម៌ និងគុណធម៌។ ជាទូទៅ មនុស្សចេះដឹងប៉ុនណាក៏ដោយ ប្រសិនបើគ្មានសីលធម៌និងចរិយាធម៌ក្នុងនោះទេ ទោះពូកែប៉ុនណា ចេះដឹងខ្លាំងប៉ុនណា ក៏មិនអាចរាប់បានថាជាមនុស្សមានតម្លៃដែរ។ តម្លៃមនុស្សពិត គឺស្ថិតនៅសីលធម៌នេះឯង។

# ឯកសារយោង


១.ប៉ាង ខាត់ ប្រវត្តិពុទ្ធសាសនានៅប្រទេសកម្ពុជា ដោយពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥០៤

២.ខៀវ ជុំ ជីវិតសន្តិភាព គ.ស.២០១៤

៣.ខៀវ ជុំ សកលចិន្តា បណ្ណាគារត្រៃរតន៍ ព.ស.២៥១៦

៤.ឆេង ផុត ព្រះពុទ្ធសាសនានិងការអប់រំសីលធម៌ខ្មែរ គ.ស.១៩៩៦

៥,ជួន ណាត វចនានុក្រមខ្មែរ ភាគ១ ភាគ២ គ.ស.១៩៧៦

៦. ឈុន គឹមអៀត ទ្រឹស្តីកម្មផល គ.ស.២០១៦

៧.ឈូក ម៉ឹងម៉ោង សុភាវធម៌ ផ្សាយដោយគ្រឹះស្ថានដាំដើមជីវិត គ.ស.២០១៤

៨.ត្រឹង ងា អរិយធម៌ខ្មែរ គ.ស.១៩៧៥

៩. ធរ សោ ព្រះពុទ្ធសាសនានិងសង្គមខ្មែរ គ.ស.១៩៩៤

១០. ធរ សោ សំណួរចម្លើយវប្បធម៌ អរិយធម៌ខ្មែរ គ.ស.១៩៩៣

១១. ធរ សោ អរិយធម៌ខ្មែរ គ.ស.១៩៩៤

១២. ប៊ុន សារង្ស ស្ត្រីក្នុងព្រះពុទ្ធសាសនា ព.ស.២៥៥១

១៣.ភិក្ខុ ធីន ភេន ឥន្ទប្បញ្ញោ ពុទ្ធោវាទសង្ខេប គ.ស.១៩៩៥

១៤.មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា ពុទ្ធសាសនាក្នុងប្រទេសកម្ពុជា គ.ស.២០១៨

១៥.រស់ ចន្ទ្រាបុត្រ ប្រវត្តិសាស្ត្រខ្មែរ គ.ស.១៩៩៧

១៦.លាង ហាប់អាន ប្រវត្តិអក្សរសាស្ត្រខ្មែរ ភាគ១ គ.ស.១៩៥៤

១៧.លី ប៊ុនលីន ទស្សនទានពុទ្ធសាសនា គ.ស.២០១៤

១៨.សមណនិស្សិតនិងនិស្សិតខ្មែរ កម្រងស្តីអំពីព្រះពុទ្ធសាសនា ព.ស.២៥៥៧

១៩.ស៊ិន គង់ ឈ្វេងយល់ពីព្រះពុទ្ធសាសនា ព.ស.២៥៥៦

២០.ហួត តាត ព្រះពុទ្ធសាសនានៅកម្ពុជា សង្ខេប ពុទ្ធសាសនបណ្ឌិត្យ គ.ស.១៩៧០

២១. ហេង មណីចិន្តា ព្រះបាទធម្មិក បោះពុម្ពផ្សាយលើកទី២ គ.ស.១៩៦៥

២២.ឡុង សារិន សាកល្បងសិក្សាអរិយធម៌ខ្មែរ គ.ស.២០០៦